# រឿងទីឃាវុកុមារ

( ចាក ធ. ខុ. )

( សេចក្តីអត់ធន់ ងាយសម្រេចប្រយោជន៍គ្រប់យ៉ាង )

កាល ព្រះបាទព្រហ្មទត្ត គ្រងរាជសម្បត្តិក្នុងក្រុងពារាណសី ដែនកាសី ព្រះបាទទីឃីតិ គ្រងរាជសម្បត្តិ ក្នុងក្រុងសាវត្ថីដែនកោសល ។

គ្រានោះព្រះបាទព្រហ្មទត្តលើកពល ទៅវាយក្រុងសាវត្ថីបាន ។ ព្រះបាទទីឃីតិ នាំព្រះអគ្គមហេសី ទៅនៅអាស្រ័យនឹងស្មូនឆ្នាំងម្នាក់ក្នុងប្រទេសមួយ ។ កន្លងផុតក្រោយមក ព្រះអគ្គមហេសីមានព្រះរាជបុត្រ សន្មតព្រះនាមថា " ទីឃាវុកុមារ " ។ វេលាមួយព្រះបាទព្រហ្មទត្ត ចាប់ព្រះបាទទីឃីតិបាន ក៏ឱ្យពេជ្ឈឃាតនាំទៅសម្លាប់ គេកំពុងបណ្តើរទៅ ទីឃាវុមកឃាត់ទាន់ ។ ព្រះបាទទីឃីតិទ្រង់ប្រដៅព្រះរាជបុត្រថា " នែទីឃាវុ ! អ្នកកុំឃើញកាលវែងពេក ខ្លីពេក ធម្មតាពៀរមិនដែលរម្ងាប់ដោយពៀរទេ ពៀរតែងរម្ងាប់ដោយការមិនចង់ពៀរ " ទ្រង់ផ្តាំស្រេច ពេជ្ឈឃាតក៏សម្លាប់ទៅ ។

ថ្ងៃក្រោយ ទីឃាវុ ចូលថ្វាយខ្លួនជាខ្ញុំរាជការយ៉ាងជិតដិតនឹង ព្រះបាទព្រហ្មទត្ត ។ សម័យមួយ ព្រះបាទព្រហ្មទត្តទ្រង់ស្តេចយាងទៅប្រពាតព្រៃ ឱ្យទីឃាវុធ្វើជានាយសាថីបររាជរថ ។
ទីឃាវុបានឱកាស ក៏ប្រឹងបររាជរថបង្ហួសទៅមុនពួកពលសេនា ដោយប្រាថ្នានឹងសម្លាប់ព្រះបាទព្រហ្មទត្តនោះ ។ វេលានោះព្រះបាទព្រហ្មទត្តទ្រង់ ផ្ទំលើភ្លៅរបស់ទីឃាវុ ដោយសេចក្តីនឿយហត់ ព្រួយព្រះកាយពល កំពុងតែផ្ទំស្កប់ ទីឃាវុចាប់ព្រះខ័នឡើងប្រាថ្នានឹងសម្លាប់ តែនឹកភ្នកដល់បណ្តាំព្រះបិតា ក៏ឈប់ទៅវិញ គ្រាន់តែស្រែកសន្ធាប់ឱ្យព្រះបាទព្រហ្មទត្ត ជ្រាបថាជាបុត្រព្រះបាទ ទីឃីតិប៉ុណ្ណោះ ។ គ្រានោះក្សត្រិយ៍ទាំង ២អង្គទ្រង់បានឱ្យជីវិតគ្នានឹងគ្នា ហើយទ្រង់ស្តេចក៏យាងត្រលប់ទៅព្រះនគរវិញ ព្រមទាំងប្រទានព្រះរាជធីតាឱ្យជាអគ្គមហេសី ។
លុះតមកខាងក្រោយ ព្រះបាទទីឃាវុបានគ្រងរាជ្យជាធំក្នុងដែនទាំង២ គឺ ដែនកាសី និងដែនកោសល ។

សូមអស់លោកអ្នកអនុមោទនា !ចប់